# សិទ្ធិនិងការទទួលខុសត្រូវ

**Rights & Responsibilities - Khmer**



icare

integrity • compassion • accountability • respect • excellence

Southern Health

Better Health for Our Community

ជាការសំខាន់ណាស់ដែលលោកអ្នកត្រូវដឹងនូវអ្វីដែលអាចទទួលបានពីសេវារបស់គេ និងបុគ្គលិក ព្រមទាំងការទទួលខុសត្រូវរបស់លោកអ្នកនៅខណៈកំពុងទទួលសេវាអស់ទាំងនេះ។ កូនសៀវភៅតូចនេះបង្ហាញជូននូវសិទ្ធិនិងការទទួលខុសត្រូវរបស់លោកអ្នកក្នុងនាមជាអ្នកប្រើប្រាស់សេវាថែទាំសុខភាពពី សោស៍ឌើន ហែលថ៍ (Southern Health)។

## លោកអ្នកមានសិទ្ធិទទួល

### ការថែទាំសុខភាពដែលមានស្តង់ដារខ្ពស់

- ចូលរួមក្នុងសេចក្តីសំរេចចិត្តនានាទាក់ទងនឹងការថែទាំសុខភាពរបស់លោកអ្នក។
- ជ្រើសរើសថាតើលោកអ្នកចង់ទទួលការព្យាបាលក្នុងលក្ខណៈជាអ្នកជំងឺឯកជនឬសាធារណៈ។
- ទទួលយកបានសេវាធំទូលាយច្រើនប្រភេទ។
- ធ្វើបណ្តឹងឬផ្តល់ការសរសើរ។

### សេវាដែលគោរពវប្បធម៌និងតម្រូវការការប្រាស្រ័យទាក់ទងរបស់លោកអ្នក

- ទទួលយកបានអ្នកបកប្រែភាសាវិជ្ជាជីវៈផ្នែកពេទ្យ។
- សេវាដែលផ្តល់ជូនដោយគោរពវប្បធម៌។

### ទទួលការព្យាបាលឬការថែទាំណាដែលលោកអ្នកបានផ្តល់ការយល់ព្រមតែប៉ុណ្ណោះ

- បដិសេធមិនទទួលការថែទាំឬការព្យាបាល (អ្នកជំងឺខ្លះនៅក្នុងច្បាប់សុខភាពខួរក្បាលមិនអាចបដិសេធមិនទទួលការព្យាបាលបានទេ)។
- សំរេចចិត្តថាតើសិស្សសុខាភិបាលអាចចូលរួមក្នុងការថែទាំសុខភាពរបស់លោកអ្នកបានឬទេ ដែលនេះជាផ្នែកមួយនៃការបណ្តុះបណ្តាលរបស់ពួកគេ។
- សំរេចចិត្តថាតើត្រូវចូលរួមក្នុងគំរោងការងារស្រាវជ្រាវឬទេ។

### ព័ត៌មានជាក់ច្បាស់អំពីស្ថានភាពសុខភាពរបស់លោកអ្នកនិងការគ្រប់គ្រង

- ទទួលការឆ្លើយតបមានខ្លឹមសារភ្លាមៗចំពោះសំណួរឬការបារម្ភទាំងឡាយដែលលោកអ្នកលើកឡើងអំពីការថែទាំសុខភាពរបស់លោកអ្នក។
- ទទួលបានព័ត៌មានអំពីភាពប្រថុយប្រថាននៃការព្យាបាល អត្ថប្រយោជន៍ និងជំរើសដទៃទៀត។
- ទទួលយកបានកំណត់ហេតុសុខភាពរបស់លោកអ្នកនៅក្រោមច្បាប់សេរីភាពព័ត៌មាន ១៩៨២។

### សេចក្តីថ្លៃថ្នូរនិងការគោរពនៅក្នុងការថែទាំរបស់លោកអ្នក

- ការពិចារណានូវតម្រូវការរៀងៗខ្លួនរបស់លោកអ្នក។
- ទទួលនូវសេវាទាំងឡាយតាមលក្ខណៈមួយដែលមិនលំអៀងឬមិនមានការវិនិច្ឆ័យ។
- ទទួលការណែនាំឲ្យស្គាល់បុគ្គលិកទាំងអស់ដែលជួយថែទាំលោកអ្នក។

### ភាពឯកជននិងភាពសំងាត់

- គោរពនូវភាពឯកជនរបស់លោកអ្នកនិងចាត់ទុកព័ត៌មានសុខភាពរបស់លោកអ្នកជាសំងាត់។
- ដំកល់ទុកនិងថែរក្សាដោយជាប់លាប់នូវកំណត់ហេតុការថែទាំសុខភាពរបស់លោកអ្នក។
- Southern Health អនុវត្តតាមតម្រូវការនានារបស់ច្បាប់ស្តីពីភាពឯកជន។

### បរិយាកាសមានសុវត្ថិភាព

- សេវាផ្តល់ជូននៅក្នុងបរិយាកាសមួយដែលអាចទទួលយកបាន ស្អាត មានសុវត្ថិភាព និងសន្តិសុខ។

### មតិយោបល់ទីពីរ

- ស្នើនិងទទួលបានមតិទីពីរស្តីអំពីការថែទាំសុខភាពរបស់លោកអ្នក។

### ការគាំទ្រពីបុគ្គលណាម្នាក់ដែលអ្នកជ្រើសរើសនៅក្នុងការពិភាក្សាពីការថែទាំរបស់លោកអ្នក

- បុគ្គលគាំទ្រម្នាក់ចូលរួមការប្រជុំនិងពិភាក្សាជាមួយបុគ្គលិក។
- តែងតាំងជាមុននូវមនុស្សម្នាក់ដើម្បីធ្វើសេចក្តីសំរេចចិត្តនៃការថែទាំសុខភាពជំនួសលោកអ្នក ប្រសិនបើនិងនៅពេលដែលលោកអ្នកមិនអាចធ្វើដូច្នេះបាន។

### ទទួលបានព័ត៌មាននៃការចំណាយនានាទៅលើសេវាថែទាំសុខភាព

# លោកអ្នកមានការទទួលខុសត្រូវក្នុងការ

## សហប្រតិបត្តិការជាមួយក្រុមព្យាបាលលោកអ្នក

- រក្សាការណាត់ជួបដែលបានរៀបចំជូនលោកអ្នក។
- យល់ដឹងពីផលវិបាកនៃការសំរេចចិត្តណាមួយដែលលោកអ្នកធ្វើក្នុងការបដិសេធការថែទាំឬការព្យាបាល។

## ផ្តល់អស់ពីសមត្ថភាពរបស់លោកអ្នកនូវព័ត៌មានដើម្បីជួយក្នុងការព្យាបាលលោកអ្នក

- ផ្តល់ព័ត៌មានត្រឹមត្រូវអំពីប្រវត្តិសុខភាពរបស់លោកអ្នកផ្ទាល់និងរបស់គ្រួសារលោកអ្នក រួមបញ្ចូលនូវព័ត៌មានអំពីឱសថ ថ្នាំ ឱសថឬសារធាតុនានាដែលលោកអ្នកកំពុងប្រើ។

## ប្រាប់យើងខ្ញុំនៅពេលដែលអ្នកមានសំណួរឬការបារម្ភអំពីការថែទាំលោកអ្នក

- សួរសំណួរនានាដូចនេះយើងអាចជួយលោកអ្នកយល់ដឹងអំពីស្ថានភាពសុខភាពរបស់លោកអ្នក ការព្យាបាល និងការថែទាំ។

## គាំទ្រយើងខ្ញុំក្នុងបរិយាកាសមួយដែលមានសុវត្ថិភាព ស្អាត និងគួរជាពេញចិត្ត

- អនុវត្តតាមបទបញ្ជានានាទាក់ទងនឹងតំបន់ហាមជក់បារីនិងការហាមឃាត់សុរានិងគ្រឿងញៀននៅតាមទីតាំងរបស់ Southern Health។
- រក្សាសំលេងឲ្យបានទាបបំផុតដែលជាអត្ថប្រយោជន៍អ្នកដែលនៅជុំវិញខ្លួនអ្នក។
- អនុញ្ញាតឲ្យបុគ្គលិកប្រើឧបករណ៍ដើម្បីជួយពួកគេលើកឬរុញលោកអ្នក។
- ទុកវត្ថុមានតំលៃរបស់លោកអ្នកនៅផ្ទះ ព្រោះថា Southern Health  មិនទទួលខុសត្រូវចំពោះការបាត់បង់ ឬខូតខាតទ្រព្យសម្បត្តិនានាដែលយកចូលក្នុងទីតាំងទេ។

## បង្ហាញការគោរពដល់ជនទាំងឡាយដែលកំពុងថែទាំលោកអ្នកនិងអ្នកដែលប្រើប្រាស់សេវារបស់យើង

- គោរពភាពឯកជន តម្រូវការនានា ភាពថ្លៃថ្នូររបស់អ្នកដទៃ ដោយចេះគួរសមនិងចេះគិតដល់អ្នកដទៃ។
- គោរពម៉ោងសួរសុខទុក្ខអ្នកជំងឺនិងអនុវត្តតាមការណែនាំសំរាប់អ្នកមកសួរសុខទុក្ខ។

## បង់ប្រាក់គណនីឲ្យទាន់ពេលវេលានិងផ្តល់ការទទួលយកបាននូវប័ណ្ណថែទាំសុខភាពរបស់លោកអ្នកនៅពេលចាំបាច់

- សូមយកព័ត៌មានលំអិតមកជាមួយ បើសិនជាលោកអ្នកមានការធានារ៉ាប់រងសុខភាពឯកជន។

## ពាក្យសរសើរ មតិយោបល់ និងភាពបារម្ភ

Southern Health ពេញចិត្តនឹងមតិយោបល់នានាស្តីអំពីសេវានិងការថែទាំដែលយើងផ្តល់ជូន។ មតិយោបល់ដែលទទួលបាន ត្រូវបានប្រើដើម្បីធ្វើឲ្យបានប្រសើរជាបន្តទៅទៀតនូវគុណភាពនៃសេវា របស់យើង។ ព័ត៌មានណាមួយដែលផ្តល់ជូននឹងមិនប៉ះពាល់ដល់ការថែទាំរបស់លោកអ្នកទេ។ លោក អ្នកនឹងទទួលបានការគោរព ហើយមតិយោបល់របស់លោកអ្នកនឹងត្រូវបានដោះស្រាយជូនឲ្យបានទាន់ពេល វេលា។

### អ្វីដែលលោកអ្នកត្រូវធ្វើប្រសិនបើមានការបារម្ភ:

- ដំបូង និយាយទៅកាន់បុគ្គលិកដែលចូលរួមក្នុងការថែទាំលោកអ្នកផ្ទាល់ ឬមួយអ្នកដែលទទួលបន្ទុកតំបន់នោះ។
- បើលោកអ្នកចង់ធ្វើពាក្យបណ្តឹង លោកអ្នកក៏អាចនិយាយជាមួយមន្ត្រីទំនាក់ទំនងបណ្តឹងផង ដែរ:

| | |
|---|---|
| មជ្ឈមណ្ឌលសុខភាពម៉ូណាស់ តំបន់ឃ្លេថុន (Clayton) | ៩៥៩៤ ២៧០២ |
| មជ្ឈមណ្ឌលសុខភាពម៉ូណាស់ តំបន់ មូរ៉ាប៊ីន (Moorabin) | ៩៩២៨ ៨៥៨៤ |
| មន្ទីពេទ្យដានឌីណុង (Dandenong) | ៩៥៥៤ ៨០៧៨ |
|ឃីងស្តុន (Kingston) | ៩២៦៥ ១០០០ |
| មន្ទីពេទ្យ ឃេស៊ី (Casey) | ៨៧៦៨ ១២០០ |
| មណ្ឌលសុខភាពសហគមន៍ (សូមទាក់ទងមណ្ឌលក្នុងតំបន់) | |

បើសិនជាលោកអ្នកចង់ធ្វើបណ្តឹងជាលាយលក្សណ៍អក្សរ សូមផ្ញើលិខិតឆ្លើយឆ្លងរបស់លោកអ្នកមក:

**Complaints and Compliments**
**Southern Health**
**Locked Bag 29**
**Clayton South VIC 3169**

ឬមួយក៏អ៊ីម៉េលមក:

**feedback@southernhealth.org.au**

បើលោកអ្នកជឿថាការបារម្ភរបស់លោកអ្នកមិនត្រូវបាន Southern Health ដោះស្រាយជូនទេ សូមទាក់ទងមក:

**The Health Services Commissioner**
**Level 30, 570 Bourke Street**
**Melbourne VIC 3000**

ទូរស័ព្ទ: ៨៦០១ ៥២០០ ឬ

ទូរស័ព្ទមិនគិតថ្លៃ: ១៨០០ ១៣៦ ០០៦

## ភាពឯកជននិងការទទួលយក

Southern Health ត្រូវការប្រមូល ប្រើ និងធានាថាភាពឯកជននៃព័ត៌មានសុខភាពរបស់លោកអ្នក ដោយអនុលោមទៅតាមច្បាប់កំណត់ហេតុសុខភាព ២០០១។ ច្បាប់នេះនិងច្បាប់សេរីភាពព័ត៌មាន ១៩៨២ ផ្តល់ជូនលោកអ្នកសិទ្ធិទទួលយកបាននូវកំណត់ហេតុសុខភាពរបស់លោកអ្នក។
ដើម្បីស្នើសុំការទទួល យកបាននូវកំណត់ហេតុសុខភាពរបស់លោកអ្នក សូមសរសេរមក:

**The FOI Officer**
**Southern Health**
**Locked Bag 29**
**Clayton South VIC 3169**

Southern Health អាចប្រើប្រាស់ព័ត៌មានសុខភាពដោយមិនចាំបាច់ទទួលការយល់ព្រមជាក់លាក់ពីលោកអ្នក:

- ប្រសិនបើចាំបាច់សំរាប់ឲ្យបុគ្គលិកផ្តល់ការព្យាបាលជូនលោកអ្នកដោយសុវត្ថិភាពនិងមានប្រសិទ្ធិភាព។
- ក្នុងគោលបំណងទទួលមូលនិធិ ការគ្រប់គ្រង ការរៀបចំផែនការ ការត្រួតពិនិត្យ ការធ្វើឲ្យបានប្រសើរ ឬការវាយតំលៃទៅលើសេវាដែលផ្តល់ជូន។ លោកអ្នកនឹងមិនត្រូវបានគេស្គាល់ទេ។
- សំរាប់ការស្រាវជ្រាវឯកភាពពីគណៈកម្មាធិការក្រមសីលធម៌។ ពួកគេនឹងវាយតំលៃគំរោងការងារស្រាវជ្រាវនិមួយៗហើយនឹងការពារភាពឯកជនរបស់ជនគ្រប់រូបដែលចូលរួម។
- នៅពេលដែលច្បាប់តម្រូវឲ្យអនុវត្តតាម យើងផ្តល់ព័ត៌មានលំអិតរបស់អ្នកជំងឺទៅខាងកាកបាទក្រហមអូស្ត្រាលី ដើម្បីតាមរកប្រភេទឈាមឬផលិតផលឈាម។ មានតម្រូវការការរាយការណ៍តាមច្បាប់ទាក់ទងទៅនឹងកុមារដែលគេគិតថាមានគ្រោះថ្នាក់។ ជំងឺឆ្លងខ្លះនឹងត្រូវជូនដំណឹងទៅក្រសួងកិច្ចបំរើការមនុស្ស។

Southern Health អាចបដិសេធមិនផ្តល់ជូនការទទួលយកបាននូវកំណត់ហេតុសុខភាពរបស់លោកអ្នក ជាផ្នែក ឬទាំងមូល ប្រសិនបើយើងជឿជាក់ដោយមានហេតុផលសមរម្យថា ការធ្វើដូចនេះនឹងអាចជាការគំរាមគំហែងធ្ងន់ធ្ងរដល់ជីវិត ឬបុគ្គលណាម្នាក់ (រួមទាំងរូបអ្នក)។ Southern Health ក៏អាចនឹងបដិសេធមិនផ្តល់ជូនការទទួលយកបាននូវព័ត៌មានដែលបានប្រគល់មកឲ្យយើងជាសំងាត់ដោយបុគ្គលណាម្នាក់ ដូចជាមិត្តភក្តិ ឬសាច់សារលោហិត។

**បើលោកអ្នកមានចម្ងល់អំពីការប្រមូល ការប្រើប្រាស់ និងការបញ្ចេញព័ត៌មានសុខភាពរបស់លោកអ្នក សូមទាក់ទងមន្ត្រីសេរីភាពព័ត៌មានរបស់ Southern Health តាមទូរស័ព្ទ (០៣) ៩៥៩៤ ២១២៣។**

The Rights and Responsibilities brochure is available in your language. Please ask a staff member at Reception.

## Arabic

منشور الحقوق والمسؤوليات متوافر بلغتكم. أطلبوه من العاملين في مكتب الاستقبال.

## Cambodian

កូនសៀវភៅស្ដីអំពីសិទ្ធិនិងការទទួលខុសត្រូវនេះ មានផ្ដល់ជូនជាភាសារបស់លោកអ្នក។ សូមសាកសួរសមាជិកបុគ្គលិកនៅកន្លែងទទួលភ្ញៀវ។

## Chinese

《權利和責任》小冊子有您所說語言的版本,請到接待處向工作人員查詢。

## Croatian

Brošura o pravima i odgovornostima može se dobiti i na vašem jeziku. Molimo zatražite je od člana osoblja na recepciji.

## Dari

جزوه حقوق و مسئولیتها بلسان شما فراهم میباشد. لطفآ از یك كارمند میز پذیرش مراجعین پرسان نمائید.

## Greek

Το φυλλάδιο μας “Δικαιώματα και Υποχρεώσεις” διατίθεται στα ελληνικά. Παρακαλούμε να ζητήσετε ένα από τα μέλη του προσωπικού στην Ρεσεψιόν.

## Italian

L’opuscolo Diritti e Responsabilità è disponibile nella tua lingua. Rivolgiti al personale presso il banco accettazione (Reception).

## Russian

Брошюра «Права и обязанности» имеется на вашем родном языке. Обратитесь к нашему работнику у приемной стойки.

## Serbian

Брошура “Права и одговорности“ је на располагању на вашем језику. Молимо вас потражите је од службеника на рецепцији.

## Somali

Buugga yare ee Xuquuqda iyo Masuuliyadaha waxaa lagu heli karaa luqaddaada. Fadlan weyddiiso shaqaalaha jooga Soo-dhaweynta.

## Spanish

El folleto Derechos y Responsabilidades está disponible en su idioma. Pídalo al personal de Recepción.

## Turkish

Haklarınız ve Sorumluluklarınız broşürü sizin dilinizde de bulunmaktadır. Lütfen görevli bir memura veya danışma masasına sorunuz.

## Vietnamese

Tại đây có sẵn tài liệu Quyền và Trách Nhiệm bằng Việt Ngữ. Xin hỏi nhân viên ở quầy tiếp tân.